ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ២៩៤៣ សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការកំណត់ស្រុកគោលដៅសម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសលេខ៩២៨ ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ

# សម្រេច

**ប្រការ១.‒**

ត្រូវបានកំណត់យកស្រុកគោលដៅចំនួន២៩ នៃខេត្តចំនួន២១ សម្រាប់បង្កើតការិយាល័យច្រកចេញចូលតែមួយក្នុងឆ្នាំ២០១៩ ដូចខាងក្រោម៖

១. **ខេត្តកណ្តាល៖** ស្រុកកណ្តាលស្ទឹង ស្រុកកោះធំ ស្រុកពញាឮ និងស្រុកមុខកំពូល

២. **ខេត្តកំពង់ចាម៖** ស្រុកព្រៃឈរ ស្រុកបាធាយ និងស្រុកចំការលើ

៣. **ខេត្តកំពត៖** ស្រុកអង្គរជ័យ និងស្រុកកំពង់ត្រាច

៤. **ខេត្តសៀមរាប៖** ស្រុកប្រាសាទបាគង និងស្រុកបន្ទាយស្រី

៥. **ខេត្តបន្ទាយមានជ័យ៖** ស្រុកថ្មពួក និងស្រុកម៉ាឡៃ

៦. **ខេត្តព្រះសីហនុ៖** ស្រុកកំពង់សិលា

៧. **ខេត្តបាត់ដំបង៖** ស្រុកភ្នំព្រឹក

៨. **ខេត្តតាកែវ៖** ស្រុកគិរីវង់

៩. **ខេត្តកំពង់ស្ពឺ៖** ស្រុកគងពិសី

១០. **ខេត្តកំពង់ឆ្នាំង៖** ស្រុកបរិបូណ៌

១១.**ខេត្តពោធិ៍សាត់៖** ស្រុកក្រគរ

១២. **ខេត្តត្បូងឃ្មុំ៖** ស្រុកមេមត់

១៣. **ខេត្តកំពង់ធំ៖** ស្រុកសន្ទុក

១៤. **ខេត្តព្រះវិហារ៖** ស្រុកជាំក្សាន្ត

១៥. **ខេត្តមណ្ឌលគិរី៖** ស្រុកកោះញែក

១៦. **ខេត្តក្រចេះ៖** ស្រុកឆ្លូង

១៧. **ខេត្តព្រៃវែង៖** ស្រុកកំពង់ត្របែក

១៨. **ខេត្តកោះកុង៖** ស្រុកមណ្ឌលសីមា

១៩. **ខេត្តស្ទឹងត្រែង៖** ស្រុកថាឡាបរិវ៉ាត់

២០. **ខេត្តរតនគិរី៖** ស្រុកកូនមុំ

២១. **ខេត្តស្វាយរៀង៖** ស្រុករមាសហែក។

**ប្រការ២.‒**

រដ្ឋបាលស្រុកគោលដៅដូចបានកំណត់ក្នុងប្រការ១ខាងលើ ត្រូវរៀបចំការិយាល័យច្រកចេញចូលតែមួយឱ្យបានសមស្របតាមប្រកាសលេខ៩២៨ប្រក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ របស់

ﾑi

ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ។

**ប្រការ៣.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គាធិការនៃអគ្គាធិការដ្ឋានក្រសួងមហាផ្ទៃ ក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលខេត្ត ក្រុមប្រឹក្សា និងអភិបាលនៃគណៈអភិបាលស្រុកគោលដៅដូចបានកំណត់ក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ..........ខែ..........ឆ្នាំ..........ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី.....ខែ..........ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល៖**

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- -ក្រសួងមុខងារសាធារណៈ
- -ក្រសួង ស្ថាប័នពាក់ព័ន្ធ
- -ដូចប្រការ៣
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ